# សាន់បេស ហ្គាមេន ខូអិលធីឌី

SUN BEST GARMENT CO., LTD

## កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១ខែ

គឺចាប់ពីថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០២២ ដល់ ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០២៣

ថ្ងៃចន្ទ ១៣រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោងដប់បួន មានកិច្ចប្រជុំមួយនៅ សាន់បេស ហ្គាមេន ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិអង្គស្នួលទី១ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានចំនួនកម្មករសរុបចំនួន១២៥៦នាក់(ស្រី១០៦១នាក់) មាននាយក ឈ្មោះ CHIANG CHUNG YU ជនជាតិចិន ជាក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ ដែលមានលោកស្រី សុខ ចាន់ណា ជាប្រធានរដ្ឋបាលប្រចាំក្រុមហ៊ុន បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១ខែ។

ជាកិច្ចចាប់ផ្តើមលោក CHIANG CHUNG YU ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ដល់ អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោក ប្រធាន អង្គប្រជុំមានមតិសម្របសម្រួលអំពីករណី ខាងលើ និងពន្យល់ពីមូលហេតុដោយសារខ្វះការបញ្ជាទិញរបស់អតិថិជនក្នុងអំឡុងពេលនេះ។

ដូចនេះ សាន់បេស ហ្គាមេន ខូអិលធីឌី និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោម:

1-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១២៥៦នាក់រយៈពេល១ខែ ដោយគិតចាប់ពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០២៣។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុនបានព្រមព្រៀម ផ្តល់ប្រាក់ឧបត្ថម្ភជូន កម្មករនិយោជិតគឺស្មើនឹង ៧០ ដុល្លារអាមេរិក សម្រាប់កម្មករនិយោជិតម្នាក់ៗ។

អង្គស្នួលថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២

**បានឃើញនិងឯកភាព**

**តំណាងកម្មករនិយោជិត**

**តំណាងក្រុមហ៊ុន**

CHIANG CHUNG YU